# សុន្ទរកថារបស់លោក យូណាមីណេ ម៉ូរីយ៉ាស៊ូ
# លេខាទី២ នៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីប្រគល់បរិក្ខាវេជ្ជសាស្ត្រក្នុងមន្ទីរពេទ្យបង្អែកអង្គរកា ខេត្តតាកែវ

ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០១៦

- **សូមគោរព លោកវេជ្ជបណ្ឌិត ហែម សាវ៉េត ប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ!**
- **សូមគោរព លោក តឹក តុងលឹម អភិបាលស្រុកត្រាំកក់**
- **សូមគោរព លោក ប្រាក់ ប៊ុនធឿន ប្រធានការិយាល័យស្រុកប្រតិបត្តិអង្គរកា**
- **សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានមកចូលរួមពិធីប្រគល់បរិក្ខាវេជ្ជសាស្ត្រនៅមន្ទីរពេទ្យបង្អែកអង្គរកា ក្នុងខេត្តតាកែវនេះ ជាមួយនឹងវត្តមានរបស់លោកវេជ្ជបណ្ឌិត ហែម សាវ៉េត ប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ។ ជាបឋម ខ្ញុំសូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅចំពោះលោកវេជ្ជបណ្ឌិត ហែម សាវ៉េត ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញមកចូលរួមក្នុងពិធីនេះ។

ខេត្តតាកែវ គឺជាតំបន់មួយនៃតំបន់សំខាន់នានា ដែលកងកម្លាំងស្វ័យការពារជប៉ុន និងមន្ត្រីស៊ីវិល ធ្លាប់ធ្វើការអោយអ៊ុនតាក់ សម្រាប់ប្រតិបត្តិការរក្សាសន្តិភាព។ នេះ ជាលើកដំបូងបំផុត ដែលថាកងកម្លាំងស្វ័យការពារជប៉ុន ត្រូវបានបញ្ជូនទៅក្រៅប្រទេស សម្រាប់ប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ ចាប់តាំងពីពេលនោះមក រដ្ឋាភិបាលជប៉ុន បាននឹងកំពុងគាំទ្រយ៉ាងខ្លាំងដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាក្នុងការកសាង និងអភិវឌ្ឍន៍ទៅលើវិស័យជាច្រើន ហើយការកែលម្អផ្នែកបរិក្ខាវេជ្ជសាស្ត្រ គឺជាផ្នែកមួយនៃបណ្តាផ្នែកដទៃទៀតដែលយើងបានយកចិត្តទុកដាក់ផងដែរ។

ដើម្បីរួចចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ជប៉ុនបានជួយបំពាក់បរិក្ខាវេជ្ជសាស្ត្រ ព្រមទាំងម៉ាស៊ីនភ្លើង នៅមន្ទីរពេទ្យបង្អែកអង្គរកាក្នុងគម្រោងនេះផងដែរ។ មុនពេលអនុវត្តគម្រោងនេះ ម៉ាស៊ីនអេកូសាស្ត្រ ម៉ាស៊ីនពិនិត្យឈាម និងម៉ាស៊ីនភ្លើងដែលមានស្រាប់នោះ គឺមានសភាចាស់ដែលមិនអាចដំណើរការបានអស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ។ ដូច្នេះ នៅពេលដាច់ភ្លើងម្តងៗ គ្រូពេទ្យមានផលលំបាកក្នុងការធ្វើពាគវិនិច្ឆ័យ ដោយសារតែមិនអាចដំណើរការបរិក្ខាវេជ្ជសាស្ត្រ និងម៉ាស៊ីនដែលចាំបាច់នានា។ បរិក្ខាវេជ្ជសាស្ត្រ និងម៉ាស៊ីនភ្លើងថ្មី ដែលបានផ្តល់ជូនតាមរយៈជំនួយឧបត្ថម្ភឥតសំណងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ជប៉ុន នឹងអនុញ្ញាតអោយអ្នកជម្ងឺកាន់តែច្រើនឡើងទទួលបានការព្យាបាលសុខភាពកាន់តែល្អប្រសើរជាងមុន ហើយយើងសង្ឃឹមថា គម្រោងនេះ នឹងរួមចំណែកជួយកែលម្អធ្វើអោយប្រសើរឡើងនូវស្ថានភាពសុខភាពនៅក្នុងតំបន់នេះ។

ជាចុងក្រោយ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាបរិក្ខាវេជ្ជសាស្ត្រ និងម៉ាស៊ីនភ្លើងទាំងនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ និងប្រើប្រាស់បានយូរអង្វែង ដើម្បីទុកជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**